# លិង្គព្រះឥសូរនៅសំបូរព្រៃគុក

លិង្គ គឺជារូបសញ្ញាមួយនៃព្រះឥសូរ។ តាមរឿងទេវកថាព្រហ្មញ្ញសាសនា សសរលិង្គព្រះឥសូរកើតឡើងនៅពេលដែលព្រះនារាយណ៍ និងព្រះព្រហ្មឈ្លោះប្រកែកគ្នាលើបញ្ហាថា តើអ្នកណាជាអាទេពទេពធំជាងគេ? រំពេចនោះសសរភ្លើងមានមុខព្រះឥសូរនៅចំកណ្តាលក៏ផុសចេញឡើងដែលមានព្រះនាមថា "ឥសូរ" (ព្រះនាមទីមួយរបស់ព្រះឥសូរ) ដែលបញ្ជាក់ថា ទ្រង់គឺជាអាទិទេពធំជាងគេបង្អស់។[១] ពេលនោះ ព្រះព្រហ្ម និងព្រះនារាយណ៍ មិនជឿ ក៏កើតទៅជាការដាក់បន្ទុរវាងព្រះឥសូរ និងអាទិទេពទាំងពីរ។ ក្នុងនោះ បន្ទុទី៣របស់ព្រះឥសូរគឺ "បើអាទិទេពទាំងពីរអាចចេញពីសសរភ្លើងនេះបាន យើងនឹងជឿថាអ្នកជាអាទិទេពកំពូល"។ មានព្រះបន្ទូលចប់ព្រះព្រហ្មនិងព្រះនារាយណ៍ក៏យល់ព្រម ហើយព្រះឥសូរក៏ទាញព្រះនារាយណ៍ចូលក្នុងសសរភ្លើងដោយថ្នមបំផុត និងទ្រង់បានចាប់គ្រវែងព្រះព្រហ្មចូលសសរភ្លើងផ្នែកខាងក្រោមភ្លាម។ ពេលនោះព្រះនារាយណ៍បានប្រើថាមពលអស់ពីព្រះកាយដើម្បីចេញឱ្យផុតពីសសរភ្លើង ហើយសសរភ្លើងក៏បានប្រេះទៅជាប្រាំបីជ្រុងនៅតែចេញរួច រីឯព្រះព្រហ្មវិញក៏ប្រឹងរហូតដល់សសរភ្លើងប្រេះបែកជាបួនជ្រុង សន្ធប់ជាច្រើនសារ ក៏នៅតែមិនរួច។[២] ហេតុដូច្នេះហើយ ទើបយើងឃើញលិង្គភាគច្រើនគេសាងសង់ជាបីផ្នែក ដែលផ្នែកខាងក្រោមរាងបួនជ្រុង តំណាងឱ្យព្រះព្រហ្ម ផ្នែកកណ្តាលរាងប្រាំបីជ្រុង តំណាងឱ្យព្រះនារាយណ៍ និងផ្នែកខាងលើរាងមូលតំណាងឱ្យព្រះឥសូរដែលជាអាទិទេពធំជាងគេក្នុងព្រហ្មញ្ញសាសនា។

ព្រះឥសូរ គឺជាអាទិទេពធំបំផុត ដែលជាជីវិតទាំងឡាយនៃពិភពលោកនេះ ម៉្លោះហើយសិល្បករខ្មែរស្ថាបនាលិង្គធ្វើជានិម្មិតរូបនៃមេជីវិតដែលបង្កើតជីវិតរស់នៅនៅលើផែនដីនេះ ដ្បិតលិង្គតែងមានទម្រជាយោនី ដូចក្នុងជំនឿជីវចលដែលជុំថ្ម ទីទួល កូនភ្នំ គេចាត់ទុកជាអ្នកតា ឬអាទិទេពប្រុស ហើយចំណែកអាទិទេពភេទស្រីវិញគេប្រៀបធៀបទៅរូងភ្នំ ឬដីដែលជានិម្មិតរូបនៃផ្ទៃមាតា។[៣] តាមរយៈសិលាចារឹកដែលគេរកឃើញនៅតំបន់ប្រាសាទសំបូរព្រៃគុក នាំឱ្យយើងស្គាល់នូវព្រះនាមសិវលិង្គមួយចំនួនដូចជា ***ស្រីប្រហសិតេស្វរ*** (Çrīprahasiteçvara) (K.440, K.442) រកឃើញនៅក្រុមប្រាសាទយាយព័ន្ធ តួប៉ម S2 និងខ្លោងទ្វារខាងកើតកំពែង[៤], ***ស្រីកទម្វេស្វរ***

[១] Giteau 1960: 11.

[២] Tagare 1987: 383-388.

[៣] Ang Choulean 1993: 198.

[៤] Cœdès 1952: 5-11.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

(Çrīkadamveçvara) (K.604) រកឃើញនៅក្រុមប្រាសាទយាយព័ន្ធ តួប៉ម S17-6[៥], **ស្រីគម្ភីរេស្វរ** (Çrīgambhĭreçvara) (K.148, K.439) រកឃើញនៅក្រុមប្រាសាទសំបូរ កំពែងខាងកើត[៦], **ស្រីរត្នេស្វរ** (Çrīratneçvara) (K.149) រកឃើញនៅក្រុមប្រាសាទសំបូរ តួប៉ម N18[៧], **ស្រីប្រជាសេស្វរ** (Çrīprajãseçvara) (K.816) រកឃើញនៅក្រុមប្រាសាទរបង់រមាស[៨], **ស្រីប្រយាកេស្វរ** (Çrīprayãkeçvara) (K.1250) រកឃើញនៅប្រាសាទលាងព្រះ។ ភស្តុតាងសិលាចារឹក និងទិន្នន័យផ្នែកបុរាណវិទ្យាដែលគេរកឃើញនៅទីនេះ បញ្ជាក់ច្បាស់ថា តំបន់សំបូរព្រៃគុកកាលពីសម័យបុរាណមានការគោរពបូជាដល់ព្រះសិវលិង្គឬព្រះឥសូរធំធេងណាស់។

លិង្គដែលគេរកឃើញនៅតំបន់សំបូរព្រៃគុក យើងអាចចែកចេញជាពីរប្រភេទធំៗ ពោល គឺ លិង្គដែលសាងនៅសម័យមុនអង្គរ (ស.វ.ទី៧-៨) និងលិង្គដែលសាងនៅសម័យអង្គរ (ស.វ.ទី១០-១១)។ ក្នុងនោះ ប្រភេទលិង្គសម័យមុនអង្គរ អាចចែកចេញជាពីរប្រភេទទៀត ដែលប្រភេទទីមួយ គឺជាលិង្គដែលមានរាងមូលតាំងពីគល់ដល់ក្បាល មានទំហំវែងឬខ្លី តូចឬធំ អាស្រ័យលើបរិបទនៃអ្នកផលិតនិងទំហំនៃប្រាសាទ។ លិង្គប្រភេទនេះ ខ្លះមានឆ្លាក់ជាបង្អួរលិង្គនៅផ្នែកខាងលើ ខ្លះទៀតក៏មិនមានដែរ (រូបលេខ១)។ ប្រភេទទីពីរនៃសិវលិង្គសម័យមុនអង្គរ គឺជាលិង្គដែលមានផ្នែកខាងក្រោមមានរាងបួនជ្រុងស្មើ និងនៅខាងលើមានរាងមូលដូចលិង្គប្រភេទទីមួយដែរ។ លិង្គប្រភេទនេះនៅផ្នែកខាងលើមានឆ្លាក់ជាស្នាមបង្អួរលិង្គរាងច្បាស់ៗជាងលិង្គប្រភេទទីមួយ ហើយជាទូទៅលិង្គប្រភេទនេះមានទំហំខ្លីៗ ពោល គឺក្បាលលិង្គមានរាងមូលស្មើជាមួយកម្ពស់គល់លិង្គ ដែលមានរាងបួនជ្រុងស្មើ (រូបលេខ២)។ សិល្បករឆ្លាក់លិង្គសម័យមុនអង្គរប្រភេទទីមួយដែលមានរាងមូលតាំងពីគល់ដល់ក្បាលរបៀបនេះ ទំនងគេចង់បង្ហាញអំពីឥទ្ធិពលដ៏ធំធេងរបស់ព្រះឥសូរក្នុងព្រហ្មញ្ញសាសនា ដ្បិតទ្រង់ជាអាទិទេពកំពូលនៅសម័យព្រាហ្មណ៍និយម (ចាប់ពីស.វ.ទី៦មុនគ.ស. ដល់ស.វ.ទី១០នៃគ.ស.)។ ចំណែកលិង្គសម័យមុនអង្គរប្រភេទទីពីរ គេឆ្លាក់ខាងលើមូល ខាងក្រោមបួនជ្រុង ក្នុងប្រវែងស្មើគ្នារបៀបនេះ ទំនងគេចង់បង្ហាញផ្នែកខាងលើតំណាងឱ្យព្រះឥសូរ និងផ្នែកខាងក្រោមតំណាងឱ្យព្រះព្រហ្ម ដែលអាទិទេពទាំងពីរមានតួនាទីជាអ្នកបង្កើតលោកដូចគ្នា។

---

[៥] កំ វណ្ណារ៉ា ២០១៩: ៣៤។

[៦] Cœdès 1952: 33.

[៧] Cœdès 1952: 29.

[៨] Cœdès 1954: 64.

*ចំណែកលិង្គសាងនៅសម័យអង្គរដែលរកឃើញនៅតំបន់ប្រាសាទសំបូរព្រៃគុក មានទម្រង់ជាទូទៅដូចលិង្គដែលរកឃើញនៅតំបន់ប្រាសាទផ្សេងៗទៀត ដែលសាងនៅសម័យអង្គរដែរ។ សិវលិង្គនេះ គេចែកចេញជាបីផ្នែក ពោល គឺផ្នែកខាងគល់លិង្គមានរាងបួនជ្រុងស្មើ ផ្នែកកណ្តាលមានរាងប្រាំបីជ្រុង និងផ្នែកខាងក្បាលមានរាងមូល។ ផ្នែកទាំងបីនៃលិង្គដែលរកឃើញមានកម្ពស់ស្មើៗគ្នា (រូបលេខ៣)។ ការសាងសង់បែបនេះ សិល្បករខ្មែរទំនងត្រាប់តាមគម្ពីរព្រហ្មញ្ញសាសនាដែលនិទានអំពីរឿងរ៉ាវសសរភ្លើង ពោល គឺខាងក្រោមរាងបួនជ្រុងស្មើតំណាងឱ្យព្រះព្រហ្ម ផ្នែកកណ្តាលរាងប្រាំបីជ្រុងតំណាងឱ្យព្រះនារាយណ៍ និងខាងលើរាងមូលតំណាងឱ្យព្រះឥសូរ។ ការដាក់ព្រះឥសូរនៅផ្នែកខាងលើបែបនេះមានន័យបញ្ជាក់ថា ទ្រង់គឺជាអាទិទេពធំជាងគេដែលជាអ្នកបង្កើតលោក និងបំផ្លាញលោក។*

*ជារួមមក យើងអាចសន្និដ្ឋានបានថា ការគោរពបូជាដល់ព្រះសិវលិង្គនៅសំបូរព្រៃគុក មានទំហំធំធេងខ្លាំងណាស់ ពោល គឺចាប់ផ្តើមតាំងពីរវាងចុងស.វ.ទី៦ ដើមស.វ.ទី៧ រហូតដល់សម័យអង្គរក្នុងស.វ.ទី១០ និងទី១១ ក៏នៅតែមានធ្វើឡើងតម្កល់នៅក្នុងប្រាសាទ ហើយគំនិតនៃការធ្វើលិង្គព្រះឥសូររវាងសម័យទាំងពីរនេះមានលក្ខណៈខុសគ្នាដូចបានរៀបរាប់ខាងលើ។*

## ឯកសារយោង


**កំ វណ្ណារ៉ា**

*២០១៩, ប្រជុំសិលាចារឹកខេត្តកំពង់ធំ, ភ្នំពេញ*

**Ang, Chouléan**

1993, Recherches récentes sur le culte des megaliths et des gottes au Cambodge, *Journal Asiatique*, No. 1-2, Tome CCLXXXI

**Coedès, George**

1952, *Inscription du Cambodge*, Vol IV, Hanoi

1954, *Inscription du Cambodge*, Vol VI, Hanoi

**Ganesh Vasudeo Tagare**

1987, The Vayu Purana, *Ancient Indian traditional and mythology series Collection Unesco d'oeuvres representatives*, Volume 37.

**Giteau, Madelein**

1960, *Guide du musée national de Phnom Penh,* 2 vol. (1. La sculpture; 2. Pièces archéologiques et stèles), Phnom Penh


*អត្ថបទដោយ៖ ម៉ង់ រ៉ាលី*




រូបលេខ១៖ លិង្គព្រះឥសូរសម័យមុនអង្គររកឃើញនៅសំបូរព្រៃគុក ប្រភេទទី១



រូបលេខ២៖ លិង្គព្រះឥសូរសម័យមុនអង្គររកឃើញនៅសំបូរព្រៃគុក ប្រភេទទី២

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ លិង្គព្រះឥសូរសម័យអង្គរកឃើញនៅសំបូរព្រៃគុក

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី